# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលា ស្តីពីធុរៈកិច្ចក្នុងវិស័យទឹកស្អាត និងពិព័រណ៍ទឹកស្អាត កម្ពុជា–ជប៉ុន



នៅព្រឹកថ្ងៃទី២៥ ខែ មករា ឆ្នាំ២០១៦ នៅសណ្ឋាគារ Inter-Continental រាជធានីភ្នំពេញ មុនអញ្ជើញបិទសិក្ខាសាលា ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបទ្វេភាគីជាមួយ ឯកឧត្តម **Kenji Kitahashi** អភិបាលក្រុង Kitakyushu នៃប្រទេសជប៉ុន



ដើម្បីសម្តែងការគួរសម និងពិភាក្សាការងារ ទាក់ ទងនិងកិច្ចពង្រឹងសហប្រតិបត្តិការលើវិស័យទឹកស្អាតរវាងទីក្រុង Kitakyushu ជប៉ុននិងក្រសួងឧស្សាហកម្ម និង សិប្បកម្ម កម្ពុជា ដែលក្នុងឱកាសនោះ ភាគីទាំងពីរបានបង្ហាញនូវជំហរសហការនិងជម្រុញលើវិស័យទឹកស្អាតនៅកម្ពុជាអាចសម្រេចបាន តាមគោលដៅអភិវឌ្ឍន៍សហសវត្សន៍ ដែលកំណត់ថាៈ ប្រជាជនរស់នៅទីប្រជុំជនយ៉ាងតិច ៨០%ទទួលបានទឹកស្អាតប្រើប្រាស់ នៅឆ្នាំ២០១៥ ៨៥% នៅឆ្នាំ២០១៨ និង១០០% នៅឆ្នាំ ២០២៥ ។ បន្ទាប់មក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ និងឯកឧត្តម Kenji Kitahashi បានអញ្ជើញចូលរួមជាគណៈអធិបតី ក្នុងពិធីបិទសិក្ខាសាលា ស្តីពីធុរៈកិច្ចក្នុងវិស័យទឹកស្អាត និងពិព័រណ៍ទឹកស្អាត កម្ពុជា–ជប៉ុន ដែលបានប្រារព្ធធ្វើរយៈពេលមួយថ្ងៃកន្លះ កន្លងមកហើយ ។

មានប្រសាសន៍បិទអង្គសិក្ខាសាលា ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានវាយតម្លៃខ្ពស់ចំពោះជោគជ័យនៃអង្គសិក្ខាសាលាចែករំលែកបទពិសោធន៍ដ៏មានសារៈសំខាន់នេះ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យទឹកស្អាតរបស់ទីក្រុង Kitakyushu មកកម្ពុជា ដែលធ្វើឱ្យកម្ពុជាទទួលបានស្នាដៃល្អលើវិស័យទឹកស្អាតនេះ ។ ជាក់ស្តែងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញទទួលបានពានរង្វាន់អន្តរជាតិ លើវិស័យទឹកស្អាតជាបន្តបន្ទាប់ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសង្កត់ធ្ងន់ថាៈជោគជ័យនៃវិស័យទឹកស្អាត របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងការទទួលបានទឹកស្អាតប្រើប្រាស់របស់ប្រជាពលរដ្ឋកម្ពុជា គឺជាការរួមចំណែកដ៏ធំធេងពីថ្នាក់ដឹកនាំទីក្រុង Kitakyushu និងអង្គការ JICA ជប៉ុន មិនអាចខ្វះបានឡើយ ។ ប្រជាជនកម្ពុជាចងចាំជានិច្ច នូវជំនួយដ៏មានអត្ថន័យនេះ និងសង្ឃឹមយ៉ាងមុតមាំ ទៅលើកិច្ចសហប្រតិបត្តិការជាបន្តទៀតរបស់ទីក្រុង Kitakyushu ដែលបច្ចុប្បន្នបានក្លាយជាសម្ព័ន្ធមេត្រី

ភាពជាមួយរាជធានីភ្នំពេញ ហើយសង្ឃឹមថា នឹងអាចមានសម្ព័ន្ធមេត្រីភាពជាមួយខេត្តសៀមរាប ដែលជាខេត្តទេសចរណ៍ដ៏សំខាន់របស់កម្ពុជាបន្ថែមទៀត ។




ឆ្លៀតនៅឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើដល់ឯកឧត្តមអភិបាលក្រុង Kitakyushu បន្តផ្តល់ជំនួយបច្ចេកទេស និងបណ្តុះបណ្តាលធនធានមនុស្សដល់កម្ពុជាបន្តទៀត ។ ក្នុងនោះការផ្តល់ជំនួយជាឧបករណ៍ធ្វើតេស្តវិភាគ និងឧបករណ៍ទំនើបទឹកស្អាតដ៏ទៃទៀត គឺជាជំនួយដែលកម្ពុជាត្រូវការបំផុត។ ក្នុងនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា:ឧបករណ៍ផលិតទឹកស្អាតនៅជប៉ុនពិតជាមានគុណភាពខ្ពស់ ដែលឯកឧត្តម ស្នើឱ្យភាគីជប៉ុនបង្កើតក្រុមហ៊ុនលក់បរិក្ខា និងក្រុមហ៊ុនបម្រើសេវាទឹកស្អាតនៅកម្ពុជាផងដែរ។ ពីព្រោះដើម្បីជួយពង្រឹងដល់វិស័យទឹកស្អាតឯកជន វិសាធារណៈ ដែលមិនទាន់ផលិតតាមស្តង់ដារគុណភាព និងការគ្រប់គ្រងល្អលើអាជីវកម្មរបស់ខ្លួន ។ បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ឯកឧត្តម Kenji Kitahashi អភិបាលក្រុង Kitakyushu និងលោក Yasuyuki Takezawa ប្រធានសមាគមអាជីវកម្មទឹកស្អាតក្រៅប្រទេសរបស់ទីក្រុង Kitakyushu បានអញ្ជើញចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការពង្រឹងវិស័យទឹកស្អាតនៅកម្ពុជា ដែលក្នុងឱកាសនោះ ក៏មានអានសារអបអរសាទររបស់រដ្ឋមន្ត្រីក្រសួង សុខាភិបាល ការងារ និងសុខមាលភាពរបស់ជប៉ុនផងដែរ ។


Japan International Cooperation Agency (JICA)
City of Kitakyushu
Kitakyushu Overseas Water Business Association(KOWBA)
January 25- 26, 2016
Phnom Penh Cambodia, INTERCONTINENTAL HOTEL
JWWA
jica
KOWBA


January 25- 26, 2016
INTERCONTINENTAL HOTEL
KOWBA